ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១៧-៤២០ ភ.ស.ស

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៧

**ជម្រាបមក**
**លោក លោកស្រី អគ្គនាយក អគ្គនាយិកា**
**គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ**

**កម្មវត្ថុ** ៖ ករណីក្រើនរំលឹកចំពោះការហាមឃាត់ទទួលយកអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ការធានាលើការផ្តល់ឥណទាន ។

**យោង** ៖ សេចក្តីជូនដំណឹងលេខ ធ៧.០១៦.២១០.សជណ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ របស់ធនាគារជាតិនៃកម្ពុជា ។

តបតាមកម្មវត្ថុ និងយោងខាងលើ ធនាគារជាតិនៃកម្ពុជា សូមជម្រាប លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងអស់ ជ្រាបថា កន្លងមក ធនាគារជាតិនៃកម្ពុជា បានជូនដំណឹងអំពីការហាមឃាត់ទទួលយកអត្តសញ្ញាណប័ណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ សម្រាប់ការធានាលើការផ្តល់ឥណទាន ។ ប៉ុន្តែ ធនាគារជាតិនៃកម្ពុជា សង្កេតឃើញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ មួយចំនួន នៅតែអនុវត្តមិនទាន់បានពេញលេញតាមសេចក្តីជូនដំណឹងខាងលើនេះ ។

ហេតុដូចនេះ ធនាគារជាតិនៃកម្ពុជា សូមរំលឹកថា គ្រឹះស្ថានទាំងអស់ត្រូវយកចិត្តទុកដាក់បន្តអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងរបស់ធនាគារជាតិនៃកម្ពុជា លេខធ៧.០១៦.២១០.សជណ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៦ ឲ្យបានពេញលេញ និងម៉ឺងម៉ាត់ ។ ក្នុងករណីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទណា នៅតែបន្តសកម្មភាព និងមិនយកចិត្តទុកដាក់អនុវត្តតាមសេចក្តីជូនដំណឹងនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទទាំងនោះ នឹងត្រូវទទួលរងទណ្ឌកម្មខាងវិន័យ និងឈានទៅរកការដកហូតអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតចុះបញ្ជី បញ្ឈប់សកម្មភាពអាជីវកម្ម ស្របតាមមាត្រា ៥២ និង ៥៦ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ជាធរមាន ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រតិបត្តិករឥណទានជនបទ ទាំងអស់ ជ្រាបនិងសហការអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់ ។

សូម លោក លោកស្រី អគ្គនាយក អគ្គនាយិកា ទទួលនូវការរាប់អានអំពីខ្ញុំ ។

**ត.ប ទេសាភិបាល**
**អគ្គនាយកត្រួតពិនិត្យ**

**រ័ត្ន សុវណ្ណោរ:**